ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Nov-2014, 14:55
CMS/CFO: Sann Rada

**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public
ឋានៈនៃចំណាត់ថ្នាក់ឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងសៀវភៅកំណត់ហេតុប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលេខសម្គាល់ 2-TCCP-296**

---

**ដាក់ដោយ:**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**
ពេជ អង្គ
Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី

**នៅចំពោះមុខ:**

**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម យូរ ឧត្តរា
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម Claudia FENZ

ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
សំ សុគង់
វ៉េន ពៅ
ទី ស្រីនណា
Emmanuel ALTIT
Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Michael Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Julien RIVET
Nushin SARKARATI
Beini YE

**ផ្ញើជូន:-**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN
យ៉េត ចរិយា
William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន
នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ
Victor KOPPE

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំដោយគោរពថា អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") មេត្តាបញ្ចូលក្នុងសំណុំរឿង និងទទួលយកជាភស្តុតាង នូវសៀវភៅកំណត់ហេតុប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-296។

២. សៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងជួយអង្គជំនុំជម្រះក្នុងការលាតត្រដាងការពិត ហើយវាប្រយោជន៍យុត្តិធម៌ដែលត្រូវទទួលយកជាភស្តុតាង ដោយសារវាពាក់ព័ន្ធជាខ្លាំងដល់ការចោទប្រកាន់នានាក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២/០២ ស្តីពីសហករណ៍ត្រាំកក់ និងទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងឯកសារនានាដែលមានក្នុងសំណុំរឿងរួចហើយ រួមទាំងសក្ខីកម្មផ្ទាល់មាត់ដែលរូបគាត់ និងសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀតបានផ្តល់ស្តីពីប្រធានបទនេះ។

## II. ច្បាប់ជាធរមាន

៣. វិធានផ្ទៃក្នុងនៃតុលាការនេះបានអនុញ្ញាតឲ្យអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការទទួលយកឯកសារជាភស្តុតាង[1] នៅពេលដែលឯកសារទាំងនេះស្របទៅតាមលក្ខណៈវិនិច្ឆ័យនៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[2]។ អង្គជំនុំជម្រះបានសម្រេចថា ភស្តុតាងដែលត្រូវបានពិចារណាតាមវិធាន ៨៧(៣) ត្រូវតែសមស្រប

---

[1] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី ៨ ថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១១ (ដែលបានចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក")។

[2] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង *ដូចយោងខាងលើ* (ចែងថា "អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក-មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ-មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍")។

នឹងបទដ្ឋាន *នៃសេចក្តីបញ្ជាក់ដំបូង* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព[3]។ ក្នុងការសម្រេចទៅលើភាពអាចជឿជាក់បាន អង្គជំនុំជម្រះបានចង្អុលបង្ហាញថា "ទោះបីជាក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក មិនបានតម្រូវក៏ដោយ ក៏សូចនានៃភាពជឿទុកចិត្ត ... អាចជួយដល់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃ ថាតើភស្តុតាងដែលលើកឡើងបំពេញលក្ខខណ្ឌនានា ដែលមាននៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង"[4]។

៤. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកភស្តុតាងថ្មីថាមានសារៈសំខាន់ដើម្បីលាតត្រដាងការពិត និងស្របតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ប្រសិនបើភស្តុតាងបែបនេះមិនអាចរកបាននៅមុនពេលបើកសវនាការ ឬមិនអាចរកឃើញបន្ទាប់ពីបានបំពេញការងារប្រកបដោយការយកចិត្តទុកដាក់ហើយ[5]។ អង្គជំនុំជម្រះនឹងចាត់ទុកថា ឯកសារនានាដែលមិនត្រូវបានបញ្ចូលក្នុងបញ្ជីដើមតាមវិធាន ៨០(៣) របស់ភាគី ជាភស្តុតាងថ្មីតាមវិធាន ៨៧(៤)[6]។

---

[3] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158" ឯកសារ **E162** កថាខណ្ឌ ២, ៣១ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (E236/4/1, E265, E271, E276, និង E276/1" ឯកសារ **E276/2** កថាខណ្ឌ ២ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (តទៅនេះហៅថា "អនុស្សរណៈឯកសារថ្មីៗ")។

[4] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** កថាខណ្ឌ ២៩ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (តទៅនេះហៅថា "សេចក្តីសម្រេចលើកំណត់ស្តាប់ចម្លើយ")។ *សូមមើល* សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩២ ទាក់ទិននឹងសូចនាអំពីការជឿទុកចិត្តចំពោះឯកសារចំនួន ៩៧៨ ដែលពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅ សម្រាប់សវនាការបីសប្តាហ៍ដំបូង ឯកសារ **E158** កថាខណ្ឌ ៣, ២៣ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ (តទៅនេះហៅថា "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩២") (ដោយបានផ្តល់នូវបញ្ជីយ៉ាងវែងនៃសូចនាអំពីភាពអាចជឿជាក់បាន រួមទាំងលក្ខណៈខាងក្នុងនានាផង (ឧ. ចំណុចសម្គាល់ផ្សេងៗ អ្នកនិពន្ធដែលមានអត្តសញ្ញាណ ភាពស៊ីសង្វាក់ខាងក្នុង នៅក្នុងខ្លឹមសារនៃឯកសារ) និង លក្ខណៈខាងក្រៅ (ឧ. បមាណីកម្ម អត្តសញ្ញាណកម្ម និងការរកឃើញ))។

[5] អនុស្សរណៈឯកសារថ្មីៗ កថាខណ្ឌ ៣។

[6] *ដូចយោងខាងលើ* កថាខណ្ឌ ២។

៥. ជាករណីលើកលែងចំពោះវិធាន ៨៧(៤) អង្គជំនុំជម្រះអាចទទួលយកភស្តុតាងថ្មីដែលមិនស្រប នឹងភាពទាន់ពេល និងលក្ខខណ្ឌនៃការបំពេញការងារដោយយកចិត្តទុកដាក់បាននៃវិធាន ប្រសិនបើ ភស្តុតាងនោះពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ឬ ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីខាងមុខ ហើយប្រយោជន៍យុត្តិធម៌តម្រូវឲ្យយកប្រភពនៃឯកសារទាំងនោះមកវាយតម្លៃរួមគ្នា[7]។ នៅពេល ដែលភាគីណាមួយស្នើសុំឲ្យទទួលយកភស្តុតាង ដោយផ្អែកលើការពាក់ព័ន្ធរបស់វាទៅនឹងសក្ខីកម្ម នាពេលខាងមុខនោះ សំណើតាមវិធាន ៨៧(៤) ត្រូវតែដាក់នៅចំពោះមុខអង្គជំនុំជម្រះយ៉ាងហោច ណាស់ឲ្យបានពីរសប្តាហ៍មុនពេលស្តាប់សក្ខីកម្មនោះ[8]។

## III. ការពិភាក្សា

៦. ភស្តុតាងថ្មីដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យទទួលយកជា ភស្តុតាង មានសៀវភៅកំណត់ហេតុប្រចាំថ្ងៃសំណេរដៃមួយដែលដើមបណ្តឹងរដ្ឋប្បវេណីមានលេខ សម្គាល់ 2-TCCP-296 បានរក្សាក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល (“DK”)។ សៀវភៅ កំណត់ហេតុប្រចាំថ្ងៃនោះមានសំណេរដៃដែលចុះកាលបរិច្ឆេទចាប់ពីថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ប៉ុន្មានខែដើមឆ្នាំ ១៩៧៩។ សៀវភៅកំណត់ហេតុប្រចាំថ្ងៃមានរៀបរាប់ដោយ សង្ខេបនូវព្រឹត្តិការណ៍នានាដែលបានកើតឡើងនាពេលនោះ រួមទាំងសកម្មភាព និងយោបល់នានា របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានរស់នៅ និងធ្វើការក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម នៅតាមសហករណ៍មួយចំនួនក្នុងស្រុកត្រាំកក់ទាំងមូល។ ជាងនេះទៀត សៀវភៅកំណត់ហេតុ ប្រចាំថ្ងៃមានបញ្ចូលនូវគំនូរព្រាង ផែនទីនៃការរៀបចំផ្ទះសម្បែងនៅទីតាំងមួយ និងមានតារាងមួយ

---

[7] *ដូចយោងខាងលើ។ សូមមើលផងដែរ* សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ **E190** ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ២១ និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង “ចម្លើយតបទៅនឹងសំណើសុំលើកទីពីររបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧(៤) ទាក់ទងនឹងឯកសារដែលប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David Chandler” ឯកសារ **E172/24/5** ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២។

[8] អនុស្សរណៈរបស់អង្គជំនុំសាលាដំបូង “ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធិភាពនៃសវនាការ” ឯកសារ **E218** ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ២២។ *សូមមើលផងដែរ* អនុស្សរណៈឯកសារថ្មីៗ កថាខណ្ឌ ២។

ដើម្បីតាមដានកាលបរិច្ឆេទក្នុងប្រក្រតីទិន។ សៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះជាមូលដ្ឋានសម្រាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីសរសេរសៀវភៅមួយក្បាលដែលត្រូវបានបញ្ចូលក្នុងសំណុំរឿងរួច ហើយ និងមានផ្នែកដែលរៀបរាប់ពីទម្រង់បែបបទស្តីពីជនរងគ្រោះរបស់គាត់ផង[9]។

## *ក. សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដាក់ទាន់ពេលនៅចំពោះមុខអង្គជំនុំជម្រះ ហើយជំហានសមស្របត្រូវបានប្រកាន់យក ដើម្បីធានាថា ភាគីអាចចូលពិនិត្យមើលភស្តុតាងបាន*

៧. សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-296 ត្រូវបានពន្យារដោយមិនកំណត់ពេល ដោយសារមេធាវីការពារក្តីធ្វើពហិការមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ហើយអង្គជំនុំជម្រះបានលុបចោលការចាប់ផ្តើមដំណើរការសវនាការស្តាប់ភស្តុតាង[10]។ ពាក់ព័ន្ធនឹងការវិវត្តន៍ទាំងនេះ លំដាប់លំដោយសក្ខីកម្មដែលនឹងត្រូវស្តាប់[11] កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មដែលបានកាត់បន្ថយត្រូវបានអង្គជំនុំជម្រះប្រកាសរួចហើយ[12] កិច្ចប្រជុំរៀបចំសវនាការបន្ថែមត្រូវបានកំណត់ពេលរួចហើយ[13] ទោះបីសវនាការស្តាប់ភស្តុតាងត្រូវបានកំណត់ថានឹងចាប់ផ្តើមដំណើរការពីថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនត្រូវបានស្តាប់សក្ខីកម្មក្នុងរយៈពេលពីរសប្តាហ៍ខាងមុខដែរ។ ហេតុនេះ សំណើនេះបានដាក់ទាន់ពេលនៅចំពោះមុខអង្គជំនុំជម្រះ។

---

[9] *សូមមើល* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុំ សុផានី ដែលមានលេខសម្គាល់ 09-VU-03554 ឯកសារ **D22/3248** ចុះថ្ងៃទី 17 April 2009 លេខ ERNs 00562753-00562947។

[10] អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះសាលាដំបូង៖ ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ឯកសារ **E320**, ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១០ (“តទៅនេះហៅថា “អនុស្សរណៈព្រមាន”)។

[11] សារអេឡិចត្រូនិកពី Ken Roberts មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនភាគី “ព័ត៌មានបន្ថែមទៀតពាក់ព័ន្ធនឹងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដំបូងៗ” ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ (ដែលបានចង្អុលបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃទី៤ នៃសវនាការស្តាប់ភស្តុតាង)។

[12] ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E316** ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ២ (ភាសាអង់គ្លេស) (ដោយបានកត់សម្គាល់ថា អង្គបុរេជំនុំជម្រះសាលាដំបូងនឹងដំណើរការសវនាការ ៣ ថ្ងៃក្នុង ១ សប្តាហ៍ ហើយនឹងផ្អាកសវនាការពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៤)។

[13] អនុស្សរណៈព្រមាន កថាខណ្ឌ ៨។

៨. ដើម្បីជួយពន្លឿនពេលវេលាដល់ភាគីក្នុងការចូលពិនិត្យមើលខ្លឹមសារនៃសៀវភៅកំណត់ហេតុប្រចាំថ្ងៃ សហមេធាវីនាំមុខបានស្នើសុំថា អង្គភាពបកប្រែភាសាគួរបកប្រែឯកសារនេះជាភាសាអង់គ្លេស និងបារាំងដោយផ្អែកលើគោលការណ៍ "អាទិភាពខ្ពស់"។

## ខ. *សៀវភៅកំណត់ហេតុប្រចាំថ្ងៃមានភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាពតាមសេចក្តីបញ្ជាក់ដំបូង*

៩. សៀវភៅកំណត់ហេតុប្រចាំថ្ងៃមានភាពពាក់ព័ន្ធ*តាមសេចក្តីបញ្ជាក់ដំបូង* ទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ដោយសារវាផ្តល់នូវភស្តុតាងដែលទាក់ទងនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌនៅសហករណ៍ត្រាំកក់។ ឯកសារនេះពិពណ៌នាអំពីការគ្រប់គ្រងនៅតាមសហករណ៍ ការងារដោយបង្ខំ ស្ថានភាពរស់នៅនិងធ្វើការនៅក្នុងសហករណ៍ និងការដ្ឋានមួយចំនួននៅទូទាំងស្រុកត្រាំកក់ និងការកត់សម្គាល់ពីកាលបរិច្ឆេទសំខាន់ៗជាច្រើនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងការប្រកាសពីរដ្ឋធម្មនុញ្ញថ្មី និងការបោះឆ្នោតជាតិទៀតផង។

១០. សៀវភៅកំណត់ហេតុប្រចាំថ្ងៃអាចជឿជាក់បាន និងមានយថាភាព*តាមសេចក្តីបញ្ជាក់ដំបូង*។ វាបង្ហាញពីសូចនាករនៃភាពជឿទុកចិត្តខាងក្នុង និងខាងក្រៅជាច្រើន។ សៀវភៅកំណត់ហេតុប្រចាំថ្ងៃត្រូវបានសរសេរក្នុងសម័យកាលនោះ ចំពោះព្រឹត្តិការណ៍នានាដែលបានសរសេរទុកដោយផ្អែកលើបទពិសោធន៍ផ្ទាល់របស់ម្ចាស់សំណេរ។ ជាងនេះទៀត ឯកសារនេះត្រូវបានសរសេរជាសំណេរដៃរបស់គាត់ផ្ទាល់តែម្តង ខ្លឹមសារ និងរចនាបទនៃកំណត់ត្រាក្នុងឯកសារនោះមានភាពស៊ីសង្វាក់គ្នានៅផ្នែកខាងក្នុង ចំណែកក្រដាស និងការចងជាសៀវភៅបង្ហាញពីភាពពុកផុយ និងសឹករេចរឹលទៅតាមអាយុកាល និងប្រភពរបស់វា។ ជាងនេះទៀត ឯកសារនេះស៊ីសង្វាក់ទៅនឹងព័ត៌មានដែលមានរៀបរាប់នៅក្នុងឯកសារនានាជាច្រើនទៀត ដែលបានបញ្ចូលក្នុងសំណុំរឿងរួចហើយ។ បើយកមកពិនិត្យដេញដោលនោះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងផ្ទៀងផ្ទាត់ថា គាត់ជាម្ចាស់សំណេរនៃសៀវភៅកំណត់ហេតុប្រចាំថ្ងៃ ហើយថាវាស្ថិតក្រោមការថែរក្សារបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល និងថា គាត់ជាម្ចាស់កម្មសិទ្ធិលើសៀវភៅនោះ ចាប់ពីពេលដែលរបបនោះបានដួលរលំទៅ។

## គ. ការទទួលយកសៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះជាភស្តុតាងគឺជាប្រយោជន៍យុត្តិធម៌

១១. សហមេធាវីនាំមុខ ទទួលស្គាល់ ថា សំណើនេះទំនងជាមិនស្របទៅនឹងបទដ្ឋាននៃការបំពេញការងារដោយយកចិត្តទុកដែលមានចែងក្នុងវិធាន ៨៧(៤) ដោយសារឯកសារយោងនានាបង្ហាញថា សៀវភៅកំណត់ហេតុប្រចាំថ្ងៃដែលសរសេរក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបោះពុម្ពជាសៀវភៅដែលបានភ្ជាប់ជាមួយទម្រង់បែបបទជនរងគ្រោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបញ្ចូលក្នុងសំណុំរឿងជាយូរមកហើយ។

១២. សហមេធាវីនាំមុខស្នើសុំដាក់ សៀវភៅកំណត់ហេតុប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅចំពោះមុខអង្គជំនុំជម្រះ ដោយផ្អែកទៅលើទម្លាប់អនុវត្តន៍ចំពោះករណីលើកលែងក្នុងការទទួលយកជាភស្តុតាងដែលមិនស្របទៅនឹងបទដ្ឋាននៃការបំពេញការងារដោយយកចិត្តទុកដាក់ នៅពេលដែលអង្គជំនុំជម្រះយល់ថា ជាប្រយោជន៍យុត្តិធម៌ក្នុងការធ្វើបែបនេះ ហើយភស្តុតាងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភស្តុតាងស្រដៀងគ្នាដែលមាននៅចំពោះមុខអង្គជំនុំជម្រះ។

១៣. សៀវភៅកំណត់ហេតុប្រចាំថ្ងៃជាឯកសារដែលបានសរសេរក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានដោយកម្រ ដែលរៀបរាប់លំអិតអំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅសហករណ៍ត្រាំកក់ និងថិរវេលាដែលព្រឹត្តិការណ៍ទាំងនោះបានកើតឡើង។ ព័ត៌មានដែលបានកត់ត្រាក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-296 នឹងក្លាយជាមូលដ្ឋាន សម្រាប់ពន្យល់អំពីភស្តុតាងនានាដែលមានរៀបរាប់លំអិតនៅក្នុងសៀវភៅរបស់គាត់ ដែលមានក្នុងសំណុំរឿងរួចហើយ ហើយដែលសហមេធាវីនាំមុខបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ជាងនេះទៀត ព័ត៌មានដែលមាននៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភស្តុតាងផ្សេងៗទៀតដែលមានក្នុងសំណុំរឿងរួចហើយ ពាក់ព័ន្ធទៅនឹងសហករណ៍នៅត្រាំកក់ រួមទាំងសក្ខីកម្មផ្ទាល់មាត់ដែលរូបគាត់ និងសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀតបានផ្តល់ស្តីពីការបង្កើត ដំណើរការ និងស្ថានភាពនានានៅតាមសហករណ៍ទាំងនេះ។

១៤. ហេតុនេះ ប្រយោជន៍យុត្តិធម៌តម្រូវថា សៀវភៅកំណត់ហេតុប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-296 គួរត្រូវបានបញ្ចូលក្នុងសំណុំរឿង និងទទួលយកជាភស្តុតាង ដើម្បីឱ្យឯកសារនេះអាចត្រូវបានយកទៅវាយតម្លៃជាមួយប្រភពផ្សេងៗទៀត។

## IV. សំណើ

**អាស្រ័យហេតុនេះ** សហមេធាវីនាំមុខសូមស្នើសុំដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

(១) **សន្និដ្ឋានថា** វាជាប្រយោជន៍យុត្តិធម៌ដែលត្រូវទទួលយកសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-296 ជាភស្តុតាង។

(២) **បញ្ចូល**សៀវភៅកំណត់ហេតុប្រចាំថ្ងៃទៅក្នុងសំណុំរឿង ០០២។ និង

(៣) **ទទួលយក**សៀវភៅកំណត់ហេតុប្រចាំថ្ងៃជាភស្តុតាង។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

| កាលបរិច្ឆេទ | នាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ | **ពេជ អង្គ**<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | **Marie GUIRAUD**<br>សហមេធាវីនាំមុខ | ភ្នំពេញ | |